**អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍**

# ឯកសារព័ត៌មាន និងលទ្ធផលសំរេចបាន

# (មករា_ធ្នូ ២០០៦)

## I. អាសយដ្ឋាន និងបុគ្គលសំរាប់ទំនាក់ទំនង :


- **ការិយាល័យអង្គការ** : ផ្ទះលេខ ៥១ ផ្លូវ២៦៥ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ១៦ ៧៧៨ ៧០១ អ៊ីម៉ែល : ard.info@yahoo.com

- **បុគ្គលទំនាក់ទំនង** : លោក សួន សុខេង នាយកប្រតិបត្តិ

ទូរស័ព្ទ : (៨៥៥) ១២ ៤៧៨ ៨៧៤ អ៊ីម៉ែល : ard.cambodia@yahoo.com


## II. ព័ត៌មានរួមរបស់អង្គការ :

អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ គឺជាអង្គការមិនមែនរដ្ឋាភិបាលមិនរកប្រាក់ចំណេញ ផ្នែកខាងអភិវឌ្ឍន៍ និងស្រាវជ្រាវ ដែលផ្តោតសំខាន់លើការងារប្រព័ន្ធអេកូឡូស៊ី កសិកម្ម និងការអភិវឌ្ឍន៍ជនបទ ដែលមានលក្ខណៈនិរន្តរភាពផ្នែកធនធានធម្មជាតិ និងបរិស្ថាន។ អង្គការ ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ២០០៥ ដោយក្រុមសមាជិកស្ថាបនិកកម្ពុជាដែលមានចំណេះដឹង និងបទពិសោធន៍ចំនួន៦រូប ព្រមទាំងមានការគាំទ្រពីសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ចំនួន៥រូប។ យើងមានឆន្ទៈ និងការតាំងចិត្តខ្ពស់ក្នុងការបំពេញការងារផ្នែកអភិរក្ស និងអភិវឌ្ឍន៍ ក្នុងគោលបំណងដើម្បីរួមចំណែកធ្វើអោយប្រសើរឡើងនូវលក្ខ័ណ្ឌរស់នៅរបស់ប្រជាកសិករក្រីក្រនៅក្នុងសហគមន៍។ អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ប្រកាន់ខ្ជាប់នូវបាវចនា **សមត្ថភាព គុណភាព និងតម្លាភាព** ដែលវាបានឆ្លុះបញ្ចាំងអោយឃើញពីការប្តេជ្ញាចិត្ត និងទទួលខុសត្រូវខ្ពស់នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនជាមួយនឹងផ្នែផ្កាដ៏ត្រចះត្រចង់ ដើម្បីផ្តល់ជាប្រយោជន៍ដល់ក្រុមគោលដៅ និងបង្កើតជាគំរូមួយសំរាប់អនុវត្តតាម។

## III. អំពីស្ថាបនិកបច្ចុប្បន្នរបស់អង្គការ :

នាពេលបច្ចុប្បន្ន មានស្ថាបនិកចំនួន ៥រូប ដែលបាន និងបន្តនូវការរួមចំណែកនៅក្នុងដំណើរការបេសកកម្ម របស់អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ តាមរយៈការផ្តល់ជាប្រឹក្សាពិគ្រោះយោបល់ និងជួយតំរង់ទិសផែនការយុទ្ធសាស្ត្រ។

**១. លោក សួន សុខេង :** កំរិតវប្បធម៌បរិញ្ញាប័ត្រផ្នែកផលិតកម្ម និងបសុព្យាបាល នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ ការងារដំបូងរបស់លោកគឺជាបុគ្គលិកអង្គការម្លប់បៃតងទទួលបន្ទុកផ្នែកអប់រំបណ្តុះបណ្តាលផ្នែកធនធានធម្មជាតិ និងបរិស្ថាន។ នៅក្នុងកំឡុងពេលនោះ ក៏ជាសកម្មជនបរិស្ថានរបស់សមាគមអភិរក្សបរិស្ថាន និងវប្បធម៌ (CEPA)។ នៅបន្ទាប់មកទៀតជាគ្រូបណ្តុះបណ្តាលផ្នែកផលិតកម្ម និងបសុព្យាបាល នៃកម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះរបស់អង្គការជំនួយប្រជាពលរដ្ឋន័រវេស្ស (NPA), ជាប្រធានគំរោងនៅអង្គការអុកស្វាមអូស្ត្រាលី, ជាអ្នកឯកទេសផ្នែករៀបចំសហគមន៍ នៃគំរោងអភិវឌ្ឍន៍ជនបទរបស់អង្គការ JICA/ JICE, ជាទីប្រឹក្សាកសិកម្ម សំរាប់គំរោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទខេត្តព្រៃវែង-ស្វាយរៀង ក្នុងក្របខ័ណ្ឌបុគ្គលិកគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងចុងក្រោយជាទីប្រឹក្សាកម្មវិធីប្រចាំខេត្តស្វាយរៀង នៃគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។ ការងារទាំងអស់របស់លោកសួន សុខេង ជាមួយអង្គការជាតិ-អន្តរជាតិ និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ គឺស្ថិតនៅក្នុងតំណែងដែលទាក់ទងដោយផ្ទាល់ទៅនឹងផ្នែកបច្ចេកទេស ការសំរបសំរួល និងការងារគ្រប់គ្រងដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ជនបទចំរុះ, ការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន ដោយផ្អែកនឹងសហគមន៍។

**ទូរស័ព្ទទំនាក់ទំនង : (៨៥៥) ១២ ៤៧៨ ៨៧៤, អ៊ីម៉េល :** ard.cambodia@yahoo.com

**២. លោក ណាំ សុខលាង :** កំរិតវប្បធម៌អនុបណ្ឌិតផ្នែកសេដ្ឋកិច្ចកសិកម្ម នៃសាកលវិទ្យាល័យ Gadjad Mada ប្រទេសឥណ្ឌូនេស៊ី និងបរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រជលផល នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ នៅក្នុងឆ្នាំ១៩៩៩-២000 លោកជាបុគ្គលិកដៃគូ នៃគំរោងគ្រប់គ្រងទឹក និងជលផលសំរាប់កម្ពុជា។ បន្ទាប់មកជាប្រធានផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវកសិកម្ម នៃអង្គការកម្ពុជា ដើម្បីអភិវឌ្ឍន៍កសិកម្ម និងឥណទាន។ នាពេលបច្ចុប្បន្ន គឺជាសាស្ត្រាចារ្យជាន់ខ្ពស់របស់សាកលវិទ្យាល័យបៀលប្រាយ។

**៣. លោក លី សុភា :** កំរិតវប្បធម៌បរិញ្ញាប័ត្រផ្នែករុក្ខកម្ម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ហើយបច្ចុប្បន្នជាបុគ្គលិករបស់អង្គការអុកស្វាមអង់គ្លេស។

**៤. លោក យី គឹមថាន :** កំរិតវប្បធម៌បរិញ្ញាប័ត្រផ្នែកក្សេត្រសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ហើយបច្ចុប្បន្នជាបុគ្គលិករបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម (CEDAC)។

**៥. អ្នកស្រី ហ៊ិន ហ៊ីន :** កំរិតវប្បធម៌បរិញ្ញាប័ត្រផ្នែកផ្សព្វផ្សាយកសិកម្ម នៃសាលាកសិកម្មជាតិព្រែកលាប។ អ្នកស្រីបំរើការជាបុគ្គលិកនៃគំរោងអភិវឌ្ឍន៍ជនបទរបស់អង្គការ JICE ដែលគាំទ្រមូលនិធិដោយ

កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ និងបន្ទាប់មកទៀតជាបុគ្គលិករបស់អង្គការសង្គ្រោះសត្វព្រៃកម្ពុជា ដែលទទួលបន្ទុកកម្មវិធីអប់រំពីធនធានធម្មជាតិ និងបរិស្ថាន។

## IV. អំពីក្រុមប្រឹក្សាពិគ្រោះយោបល់ :

**១. លោក ថ្វាំ ខ៊ា (ប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់) :** កំរិតវប្បធម៌អនុបណ្ឌិត ផ្នែកការគ្រប់គ្រងការអភិវឌ្ឍន៍ និងបរិញ្ញាប័ត្រផ្នែកកសិក្សេត្រសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ លោកមានបទពិសោធន៍ការងាររយៈពេល៩ឆ្នាំ ជាមួយអង្គការអន្តរជាតិ និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ជាមួយតំណែងតួនាទីជាន់ខ្ពស់ផ្នែកបច្ចេកទេស ការសំរបសំរួល និងការគ្រប់គ្រង ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ជនបទចំរុះ, ការអភិវឌ្ឍន៍កសិកម្ម, ការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកសហគមន៍ និងការអភិរក្សនៅតំបន់ដីសើម។ បច្ចុប្បន្នលោកជាតំណាងប្រចាំប្រទេស នៃអង្គការ HEKS នៅកម្ពុជា។

**ទូរស័ព្ទទំនាក់ទំនង : (៨៥៥) ១២ ៣៨៥ ២២២, អ៊ីម៉ែល :** heks.cambodia@online.com.kh

**២. អ្នកស្រី PRIVAN LIMPANBOON :** កំរិតវប្បធម៌អនុបណ្ឌិតផ្នែកសេដ្ឋកិច្ចការងារ និងការគ្រប់គ្រងធនធានមនុស្ស នៃសាកលវិទ្យាល័យជូឡាឡុងកន ទីក្រុងបាងកក ប្រទេសថៃ។ អ្នកស្រីចាប់ផ្តើមការងារដំបូងនៅក្នុងឆ្នាំ១៩៨៧ នៅប្រទេសថៃឡង់ ក្នុងតួនាទីជាអ្នកសំរបសំរួលផ្នែកអប់រំកំរិតបឋមសិក្សា នៅសហព័ន្ធសង្គ្រោះកុមារ របស់សហរដ្ឋអាមេរិក, ជាបុគ្គលិកផ្នែកភ័ស្តុភាសេវាសង្គម នៃការិយាល័យកាតូលិក សំរាប់ជនភៀសខ្លួន និងសង្គ្រោះបន្ទាន់ (COERR)។ ចាប់ពីចុងឆ្នាំ១៩៨៩ រហូតដល់បច្ចុប្បន្ន អ្នកស្រីបំរើការងារនៅព្រះរាជាណាចក្រកម្ពុជាជាមួយអង្គការជាច្រើនដែលផ្តោតសំខាន់លើកម្មវិធីអភិវឌ្ឍន៍ចំរុះ ដូចជានៅអង្គការរ៉េដបាណាកម្ពុជា (Redd Barna), អង្គការសង្គ្រោះកុមារន័រវេស្សន៍ ( Norwegian Save the Children ), ដៃគូដើម្បីអភិវឌ្ឍន៍នៅប្រទេសកម្ពុជា (PADEK), អង្គការអុកស្វាមអង់គ្លេស និងអៀកឡង់, អង្គការឃែរ (CARE/RLU), អុកស្វាមអូស្ត្រាលី, ជំនួយប្រជាពលរដ្ឋន័រវេស្សន៍, គំរោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដែលគាំទ្រមូលនិធិដោយអភិវឌ្ឍន៍អាស៊ី, អង្គការ AUSCARE , អង្គការជនពិការអន្តរជាតិរបស់ប្រទេសបែលស៊ិក-កម្ពុជា, ជាទីប្រឹក្សាក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកិច្ចការនារី។

**ទូរស័ព្ទទំនាក់ទំនង : (៨៥៥) ១២ ១៩ ៥៩៥ ៧៤, អ៊ីម៉ែល :**p.limpanboon@online.com.kh

**៣. អ្នកស្រី RUTH BOTTOMLEY:** កំរិតវប្បធម៌អនុបណ្ឌិតផ្នែកសិល្បៈពីសាកលវិទ្យាល័យ Sussex។ អ្នកស្រីរស់នៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៤ និងបានបំរើការងារនៅក្នុងផ្នែកបរិស្ថាន, ការអភិវឌ្ឍន៍សហគមន៍ និងគំរោងសកម្មភាពមីន។ អ្នកស្រីបំរើការងារនៅក្នុងអង្គការជនពិការអន្តរជាតិរបស់ប្រទេសបែលស៊ិករយៈពេល២ឆ្នាំ, ក្នុងអំឡុងពេលនោះ អ្នកស្រីបានធ្វើការស្រាវជ្រាវស្តីពីសកម្មភាពបោសសំអាតមីនតាមភូមិ ហើយអ្នកស្រីបំរើការជាទីប្រឹក្សាបច្ចេកទេសអោយមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (CMAC) នៅក្នុងការអភិវឌ្ឍន៍សំរាប់សហគមន៍ នៃគំរោងកាត់បន្ថយគ្រោះថ្នាក់ដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។ បច្ចុប្បន្ន អ្នកស្រីបំរើការ

ងារនៅអង្គការជំនួយប្រជាពលរដ្ឋន័រវេស្សន៍ (NPA) ជាទីប្រឹក្សាស្រាវជ្រាវថ្នាក់តំបន់ ប្រចាំនៅប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម។

**ទូរស័ព្ទទំនាក់ទំនង : (៨៥៥) ១២ ៨០១ ៩៩៣, អ៊ីម៉េល :** ruth@online.com.kh

**៤. លោក ឈុំ សុវណ្ណី :** ក៏រិតវប្បធម៌អនុបណ្ឌិតវិទ្យាសាស្ត្រផ្នែកគ្រប់គ្រងធនធានព្រៃឈើតំបន់ត្រូពិច នៅសាកលវិទ្យាល័យពុត្រាម៉ាឡេស៊ី ( University Putra Malaysia ) និងបរិញ្ញាប័ត្រផ្នែករុក្ខកម្ម នៃសាកលវិទ្យាល័យភូមិន្ទ កសិកម្ម។ លោកបានចាប់ផ្តើមការងារជាមន្ត្រីផ្នែកព្រៃឈើនៅរដ្ឋបាលព្រៃឈើតាំងពីឆ្នាំ១៩៩២។ ចាប់ពីឆ្នាំ២០០១ ដល់២០០៣ លោកបានបំរើការងារជាទីប្រឹក្សាស្រាវជ្រាវផ្នែកសហគមន៍ព្រៃឈើ នៅគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន (PLG/UNDP)។ ពីឆ្នាំ២០០៣ ដល់២០០៥ លោកបំរើការជាទីប្រឹក្សាផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៃកម្មវិធីសិលាខេត្តពោធិសាត់។ បច្ចុប្បន្ន លោកជាអ្នកសំរបសំរួលកម្មវិធីជំនួយខ្នាតតូចរបស់កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ។

**ទូរស័ព្ទទំនាក់ទំនង : (៨៥៥) ១២ ៩១៩ ០៤១, អ៊ីម៉េល :** chhum.sovanny@undp.org

**៥. លោកបណ្ឌិត ស៊ុន សុត :** ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យចំរើនបច្ចេកពហុវិទ្យា។

## V. អំពីឧត្តមទស្សនៈវិស័យ បេសកកម្ម និងកម្មវិធីរបស់អង្គការ

### ១. ឧត្តមទស្សនៈវិស័យ :

សង្គមកម្ពុជាមួយ ដែលប្រជាពលរដ្ឋមានសមត្ថភាព ប្រកបដោយគុណភាព និងប្រសិទ្ធិភាពចេះជួយគ្នាទៅវិញទៅមក ព្រមទាំងរស់នៅក្នុងជីវភាពមួយដែលលក្ខណៈថ្លៃថ្នូរ និងពោរពេញទៅដោយបរិស្ថានល្អ។

### ២. បេសកកម្ម :

សមត្ថភាពរបស់និស្សិត និងក្រុមប្រឹក្សាឃុំ ត្រូវបានបង្កើនឡើង ដើម្បីជួយអោយពួកគេអាចចូលរួមចំណែកប្រកបដោយប្រសិទ្ធិភាពនៅក្នុងការអភិវឌ្ឍន៍សង្គមកម្ពុជា ដែលមាននិរន្តរភាព តាមរយៈការផ្ទេរបន្តនូវចំណេះដឹងបទពិសោធន៍ ព្រមទាំងផ្តល់អំណាច និងធ្វើការជាមួយប្រជាកសិករក្រីក្រនៅតំបន់ជនបទ។

### ៣. កម្មវិធី :

**ក. កម្មវិធីកសាងសមត្ថភាព ស្រាវជ្រាវ និងបោះពុម្ព :**

គឺជាកម្មវិធី ដែលមានគោលដៅបង្កើត និងបង្កើននូវសមត្ថភាពប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសដល់សយុវនិស្សិត និងក្រុមប្រឹក្សាឃុំ ដែលជាស្នូលដ៏សំខាន់នៅក្នុងការចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងសង្គមជាតិ។ ការបណ្តុះបណ្តាលមុខជំនាញខ្លីៗ ការចុះស្រាវជ្រាវ ការបោះពុម្ពឯកសារជំនួយស្មារតី ការបង្កើតបណ្ណាល័យ សិក្ខាសាលា វីព្រឹត្តិការណ៍ពិសេសៗ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងតំរូវការ

ជាក់ស្តែងរបស់ក្រុមគោលដៅ និងសង្គមជាតិ ដោយផ្តោតជាអាទិភាពចំពោះការងារអភិវឌ្ឍន៍សហគមន៍ ការគ្រប់គ្រងធនធាន ធម្មជាតិ និងបរិស្ថាន អភិបាលកិច្ចល្អ និងការលើកស្ទួយសេដ្ឋកិច្ចគ្រួសារ ។

**ខ. កម្មវិធីអភិវឌ្ឍន៍អភិវឌ្ឍន៍សហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន :**

គឺជាកម្មវិធីដែលមានគោលដៅចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ តាមរយៈការបណ្តុះបណ្តាល ផ្សព្វផ្សាយបច្ចេកទេសកសិកម្មសមស្រប ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ប្រកបដោយនិរន្តរភាព និងការចងក្រងក្រុមកសិករ សហគមន៍ ដោយផ្តល់នូវសិទ្ធិអំណាចពេញលេញក្នុងការចូលរួមសកម្មភាព និងធ្វើសេចក្តីសំរេចចិត្តនានា ដើម្បីលើកស្ទួយកំរិតជីវភាពរស់នៅរបស់គ្រួសារ និងសហគមន៍របស់ខ្លួន ។

**គ. កម្មវិធីផ្តល់សេវាកម្មដើម្បីនិរន្តរភាពអង្គការ :**

គឺជាកម្មវិធីដែលផ្តល់នូវសេវាកម្មនានាទៅដល់អង្គការ ស្ថាប័នដទៃទៀតទៅតាមតំរូវការ ក្នុងគោលដៅចូលរួមចំណែកធ្វើអោយប្រសើរឡើងដល់ការអនុវត្តគំរោងរបស់ខ្លួន និងធានានូវនិរន្តរភាពនូវដំណើរការសកម្មភាពរបស់អង្គការ ។ សេវាកម្ម ដែលនឹងត្រូវផ្តល់ទាំងនោះ រួមមាន :

- ការបណ្តុះបណ្តាលទៅតាមប្រធានបទនានាដែលទាក់ទងផ្ទាល់ជាមួយនឹងគំរោងអភិវឌ្ឍន៍សហគមន៍ ចំរុះ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
- ការសិក្សាអង្កេត ករណីសិក្សា រឺស្រាវជ្រាវ ដែលផ្តោតលើស្ថានភាព ផលប៉ះពាល់ នៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច ធនធានធម្មជាតិ និងបរិស្ថាន
- ការវាយតំលៃជនបទដោយមានការចូលរួម
- ការតាមដាន និងវាយតំលៃគំរោងនានារបស់អង្គការ ស្ថាប័នផ្សេងៗ ។

## VI. លទ្ធផល និងបទពិសោធន៍ការអនុវត្តគំរោងកន្លងមក :

នៅក្រោយពីទទួលបានលិខិតទទួលស្គាល់ស្តីពីការបង្កើតអង្គការនាចុងខែធ្នូ ឆ្នាំ២០០៥រួចមក អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានចាប់ផ្តើមដំណើរការសកម្មភាពរបស់ខ្លួនចាប់តាំងពីខែមីនា ឆ្នាំ២០០៦ មក ដែលក្នុងនោះយើងសំរេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម :

**១. ការអភិវឌ្ឍន៍ធនធានមនុស្ស :**

វគ្គបណ្តុះបណ្តាល ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ដែលផ្តោតជាសំខាន់សំរាប់និស្សិតដែលកំពុងសិក្សា និងទើបបានបញ្ចប់ការសិក្សាថ្មីៗពីមហាវិទ្យាល័យនានា ដែលសរុបរហូតមកដល់សព្វថ្ងៃនេះ អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ **បានបណ្តុះបណ្តាលដល់និស្សិតសរុបចំនួន ១៤៣នាក់ (ស្រី ៤៤នាក់)** ដែលវគ្គបណ្តុះបណ្តាលទាំងនោះ មាន :

**ក. វគ្គស្ដីពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន :** វគ្គបណ្ដុះបណ្ដាលបានដំណើរការទៅដោយមានការចូលរួមពី**សិក្ខាកាមសរុបចំនួន ២៦នាក់ (ស្រី១១នាក់)** មកពីមហាវិទ្យាល័យនានាដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលកវិទ្យាល័យភូមិន្ទភ្នំពេញ, សាលកវិទ្យាល័យន័រតុន, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងពីវិទ្យាស្ថានបណ្ដុះបណ្ដាល ព្រមទាំងពីអង្គការមួយចំនួនទៀត។ វគ្គបណ្ដុះបណ្ដាល ផ្ដោតសំខាន់ទៅលើប្រធានបទសំខាន់ៗដូចខាងក្រោម :

- ចំណេះដឹងជាមូលដ្ឋានអំពីធនធានធម្មជាតិ និងបរិស្ថាន, ប្រភេទ និងចំណាត់ថ្នាក់ធនធានធម្មជាតិ និងបរិស្ថាន
- បញ្ហាបរិស្ថាន និងធនធានធម្មជាតិ ដែលកំពុងប្រឈមមុខបច្ចុប្បន្ន
- ប្រព័ន្ធជីវៈចំរុះ និងការអភិរក្ស, ខ្សែចង្វាក់អាហារ
- ធនធានទឹក និងបញ្ហា
- ធនធានជលផល និងបញ្ហា, ដំណើរការបង្កើតសហគមន៍នេសាទ
- ធនធានដី និងបញ្ហា
- ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងឥទ្ធិពលរបស់វា
- ធនធានព្រៃឈើ និងសត្វព្រៃ, ដំណើរការបង្កើតសហគមន៍ព្រៃឈើ
- ការវាយតំលៃជនបទដោយមានការចូលរួម

នៅក្រោយពីការបណ្ដុះបណ្ដាលជាទ្រឹស្ដី សិក្ខាកាមទាំងអស់ត្រូវបានចុះសិក្សាអង្កេតផ្ទាល់នៅតាមអង្គការ និងសហគមន៍មួយចំនួន ដើម្បីស្វែងយល់អោយកាន់តែស៊ីជំរៅទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងសរសេរជារបាយការណ៍ដើម្បីការពារបញ្ចប់វគ្គ ដោយមានការចូលរួមពីគណៈកម្មការវាយតំលៃវគ្គដែលមានសមាសភាពមកពីបណ្ដាអង្គការផ្សេងៗដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការអនុវត្តគំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។

**ខ. វគ្គស្ដីពីការងារអភិវឌ្ឍន៍សហគមន៍ :** វគ្គបណ្ដុះបណ្ដាលបានដំណើរការទៅដោយមានការចូលរួមពី**សិក្ខាកាមសរុបចំនួន ៤០នាក់ (ស្រី១២នាក់)** មកពីមហាវិទ្យាល័យនានា ដូចជាសាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលកវិទ្យាល័យភូមិន្ទភ្នំពេញ, សាលកវិទ្យាល័យន័រតុន, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងពីវិទ្យាស្ថានបណ្ដុះបណ្ដាល ព្រមទាំងពីអង្គការមួយចំនួនទៀត។ វគ្គបណ្ដុះបណ្ដាល ផ្ដោតសំខាន់ទៅលើប្រធានបទសំខាន់ៗដូចខាងក្រោម :

- ចំណេះដឹងជាមូលដ្ឋានអំពីការងារអភិវឌ្ឍន៍, អត្ថន័យនៃការអភិវឌ្ឍន៍, មូលហេតុ និងគោលបំណងនៃការអភិវឌ្ឍន៍, គោលការណ៍នៃការអភិវឌ្ឍន៍ដោយយកប្រជាពលរដ្ឋជាធំ
- គោលការណ៍សំខាន់ៗក្នុងការអភិវឌ្ឍន៍សហគមន៍, គោលការណ៍ណែនាំសំរាប់អ្នកធ្វើការក្នុងសហគមន៍, គុណភាព និងតួនាទីរបស់អ្នកធ្វើការក្នុងសហគមន៍

- ការរៀបចំសហគមន៍ ៖ គោលការណ៍គន្លឹះស្តីពីការរៀបចំសហគមន៍, ការដឹកនាំ និងការធ្វើសេចក្តីសំរេចចិត្តនៅក្នុងសហគមន៍
- ទស្សនៈទានស្តីពីយេនឌ័រនៅក្នុងការងារអភិវឌ្ឍន៍
- វិធីសាស្រ្តសំរបសំរួល និងការធ្វើការងារជាក្រុម
- ការវិភាគបញ្ហា, វិភាគគោលបំណង និងដំណោះស្រាយ
- ការធ្វើផែនការ, ផែនការសកម្មភាព និងផែនការថវិកា
- ការតាមដាន ត្រួតពិនិត្យ និងវាយតំលៃ

នៅក្រោយពីការបណ្តុះបណ្តាលជាទ្រឹស្តី សិក្ខាកាមទាំងអស់ត្រូវបានចុះសិក្សាអង្កេតផ្ទាល់នៅតាមអង្គការ និងសហគមន៍មួយចំនួន ដើម្បីស្វែងយល់អោយកាន់តែស៊ីជំរៅទាក់ទងនឹងការងារអភិវឌ្ឍន៍សហគមន៍ និងសរសេរជារបាយការណ៍ដើម្បីការពារបញ្ចប់វគ្គ ដោយមានការចូលរួមពីគណៈកម្មការវាយតំលៃវគ្គ ដែលមានសមាសភាពមកពីបណ្តាអង្គការផ្សេងៗដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការអនុវត្តគំរោងអភិវឌ្ឍន៍សហគមន៍។ ប្រធានបទដែលត្រូវបានជ្រើសរើសដើម្បីចុះសិក្សាអង្កេតសំរាប់វគ្គបណ្តុះបណ្តាលនេះ រួមមាន ៖

- ការសិក្សាអង្កេតពីកម្មវិធីឡជីវឧស្ម័ន របស់មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍កសិកម្ម និងការចិញ្ចឹមសត្វ (CelAgrid)
- ការសិក្សាអង្កេតពីការចិញ្ចឹមមាន់ និងជន្លេន របស់មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍កសិកម្ម និងការចិញ្ចឹមសត្វ (CelAgrid)
- ការសិក្សាអង្កេតពីដំណើរការកម្មវិធីចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារនៅភូមិទឹកនឹម ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល របស់មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍កសិកម្ម និងការចិញ្ចឹមសត្វ (CelAgrid)
- ការសិក្សាអង្កេតពីការបង្កើត និងដំណើរការ ក្រុមធនាគារស្រូវនៅភូមិកាប់លាវ ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលរបស់អង្គការទស្សនៈពិភពលោក (World Vision)
- ការសិក្សាអង្កេតពីការបង្កើត និងដំណើរការ ក្រុមសន្សំនៅភូមិកាប់លាវ ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលរបស់អង្គការទស្សនៈពិភពលោក (World Vision)
- ការសិក្សាអង្កេតពីដំណើរការជ្រើសរើស និង ចងក្រងក្រុមកសិករគោលដៅ នៅភូមិខ្នារ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ របស់អង្គការជំនួយដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDAO)
- ការសិក្សាអង្កេតពីការអនុវត្តន៍កម្មវិធីឥណទានសំរាប់គ្រួសារកសិករក្រីក្រនៅជនបទ ភូមិខ្នារ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ របស់អង្គការជំនួយដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDAO)
- ការសិក្សាអង្កេតពីការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍កសិកម្ម នៅភូមិខ្នារ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ របស់អង្គការជំនួយដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDAO)

**គ. វគ្គគ្រប់គ្រងគំរោង :** វគ្គបណ្តុះបណ្តាលបានដំណើរការទៅដោយមានការចូលរួមពី**សិក្ខាកាមសរុបចំនួន ២១នាក់ (ស្រី៣នាក់)** មកពីមហាវិទ្យាល័យនានាដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សាលកវិទ្យាល័យន័រតុន, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងពីវិទ្យាស្ថានបណ្តុះបណ្តាល ព្រមទាំងពីអង្គការមួយចំនួនទៀត។ វគ្គបណ្តុះបណ្តាល ផ្តោតសំខាន់ទៅលើប្រធានបទសំខាន់ៗ ដូចខាងក្រោម :

- សេចក្តីផ្តើមអំពីការគ្រប់គ្រងគំរោង : តើអ្វីជាគំរោង, តើអ្វីជាការគ្រប់គ្រងគំរោង, វដ្តនៃគំរោង
- ជំហាននៃការធ្វើផែនការដោយផ្តោតលើគោលបំណង OOPP
- ការវិភាគបញ្ហា (ដើមឈើបញ្ហា), ការវិភាគពីគោលបំណង (ដើមឈើគោលបំណង) និងការវិភាគពីដំណោះស្រាយ
- អំពី Logical Frame Work
- ការធ្វើផែនការសកម្មភាព និងផែនការថវិកា
- ការត្រួតពិនិត្យ និងវាយតំលៃគំរោង
- ការណែនាំអំពីការបង្កើតជាសំណើរគំរោង

នៅក្រោយពីការបណ្តុះបណ្តាលជាទ្រឹស្តី សិក្ខាកាមទាំងអស់ត្រូវបានចែកជាក្រុមពិភាក្សា ដើម្បីរៀបចំអោយចេញជាគំរោងមួយ ដើម្បីស្វែងយល់អោយកាន់តែស៊ីជំរៅទាក់ទងនឹងការគ្រប់គ្រងគំរោង និងការពារគំរោងដែលក្រុមខ្លួនបានបង្កើតនោះដើម្បីបញ្ចប់វគ្គ ដោយមានការចូលរួមពីគណៈកម្មការវាយតំលៃវគ្គ ដែលមានសមាសភាពមកពីបណ្តាអង្គការផ្សេងៗដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការអនុវត្តគំរោងអភិវឌ្ឍន៏នានា។

**ឃ. វគ្គជំនាញសំរបសំរួល :** វគ្គបណ្តុះបណ្តាលបានដំណើរការទៅដោយមានការចូលរួមពី**សិក្ខាកាមសរុបចំនួន ២៨នាក់ (ស្រី៦នាក់)** មកពីមហាវិទ្យាល័យនានាដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សាលកវិទ្យាល័យន័រតុន, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងពីវិទ្យាស្ថានបណ្តុះបណ្តាល ព្រមទាំងពីអង្គការមួយចំនួនទៀត។ វគ្គបណ្តុះបណ្តាល ផ្តោតសំខាន់ទៅលើប្រធានបទសំខាន់ៗ ដូចខាងក្រោម :

- អត្ថន័យនៃការសំរបសំរួល និងកត្តាសំខាន់ៗដែលនាំអោយការសំរបសំរួលមានប្រសិទ្ធិភាព
- សារៈសំខាន់នៃការសំរបសំរួល និងកត្តាសំខាន់របស់អ្នកសំរបសំរួលល្អ
- វិធីសាស្ត្រជំរុញអោយសិក្ខាកាមមានការចូលរួម
- តួនាទី ការទទួលខុសត្រូវរបស់អ្នកសំរបសំរួល
- លក្ខណៈសម្បត្តិដែលអ្នកសំរបសំរួល ត្រូវមាន និងចំនុចសំខាន់ៗ ដែលអ្នកសំរបសំរួលត្រូវជៀសវាង
- វិធីសាស្ត្រសំខាន់ៗក្នុងការសំរបសំរួល : ការបំផុសគំនិត, ការពិភាក្សាជាក្រុម, ការធ្វើបង្ហាញ, ការសំដែងតួ, ករណីសិក្សា, ការឧទ្ទេសនាម, ទស្សនៈកិច្ចសិក្សា, ល្បែងពញ្ញាក់អារម្មណ៍

- ជំនាញក្នុងការសួរសំណួរ, ជំនាញក្នុងស្តាប់, ជំនាញក្នុងការធ្វើបង្ហាញ, ជំនាញក្នុងការប្រាស្រ័យទាក់ទង
- សារសៈសំខាន់ នៃការរៀបចំប្រជុំ, ការរៀបចំត្រៀមមុនការប្រជុំ, ការរៀបចំកៅអីសំរាប់ការប្រជុំ
- ភាពខុសគ្នា នៃការរៀបរបស់កុមារ និងការរៀនរបស់មនុស្សចាស់
- ការរៀបចំគំរោងមេរៀន

នៅក្រោយពីការបណ្តុះបណ្តាលជាទ្រឹស្តី សិក្ខាកាមទាំងអស់ត្រូវបានចែកជាក្រុមពិភាក្សា ដើម្បីរៀបចំសរសេរជាគំរោងមេរៀន ខ្លឹមសារមេរៀន សំភារៈសំរាប់បណ្តុះបណ្តាល ដើម្បីធ្វើការសំរបសំរួលលើមេរៀន ដែលបានជ្រើសរើសនោះ ដោយមានការចូលរួមពីគណៈកម្មការវាយតំលៃវគ្គ ដែលមានសមាសភាពមកពីបណ្តាអង្គការផ្សេងៗ។

**១. សិក្ខាសាលាស្តីពីការអភិវឌ្ឍន៍អាជីពការងារ :** សិក្ខាសាលាបានដំណើរការទៅដោយមានការចូលរួមពីសិក្ខាកាមសរុបចំនួន ២៦នាក់ (ស្រី១២នាក់) មកពីមហាវិទ្យាល័យនានាដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សាលកវិទ្យាល័យន័រតុន, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងពីវិទ្យាស្ថានបណ្តុះបណ្តាល ព្រមទាំងពីអង្គការមួយចំនួនទៀត។ សិក្ខាសាលា ផ្តោតសំខាន់ទៅលើប្រធានបទសំខាន់ៗ ដូចខាងក្រោម :

- ប្រភព និងប្រភេទការងារ ដែលមាននាពេលបច្ចុប្បន្ន
- ការសិក្សាពីដំណឹងជ្រើសរើសបុគ្គលិក និងកត្តាផ្សេងៗដើម្បីពិចារណាក្នុងការដាក់ពាក្យ
- វិធីសាស្រ្ត និងរបៀបសរសេរប្រវត្តិរូបសង្ខេប និងលិខិតដាក់ពាក្យធ្វើការងារ
- ការត្រៀមខ្លួនដើម្បីប្រកួតប្រជែង (សំភាសន៍)
- ចំនុចសំខាន់ៗ និងអាកប្បកិរិយាដែលត្រូវប្រកាន់យកក្នុងពេលសំភាសន៍
- ចំនុចសំខាន់ៗ ដើម្បីអោយអាជីពការងារទទួលបានជោគជ័យ និងមានការអភិវឌ្ឍន៍។

**២. ការបោះពុម្ព និងបង្កើតបណ្ណាល័យ :** ដើម្បីចូលរួមចំណែកនៅក្នុងការពង្រឹងចំណេះដឹង និងធ្វើការផ្សព្វផ្សាយអំពីតក្កភាពដែលបាន និងកំពុងកើតមានឡើងនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ជាពិសេសផ្តោតលើការងារអភិវឌ្ឍន៍ និងជីវិតពិតរបស់ប្រជាពលរដ្ឋខ្មែរយើង អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បាន :

- **បោះពុម្ពជាព្រឹត្តិបត្តិព័ត៌មានប្រចាំខែ** ដែលបានចាប់ផ្តើមដំណើរការចាប់តាំងពីខែតុលា ឆ្នាំ២០០៦ កន្លងមក។ ព្រឹត្តិបត្តិព័ត៌មាននេះមានឈ្មោះថា **ព័ត៌មានសំខាន់សំរាប់អ្នក** ដែលសរុបមានចំនួន ១០ ទំព័រ គឺទំព័រមុខ (បង្ហាញអំពីឈ្មោះ អាសយដ្ឋានអង្គការ និងមាតិកាព័ត៌មានសំរាប់ខែដែលចេញផ្សាយ), ទំព័រស្តីពីពត៌មានពីសកម្មភាពរបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍។ ទំព័រឱកាសសំរាប់អ្នក (ទំព័រទី៣ និងទី៤) គឺជាទំព័រដំណឹងជ្រើសរើសបុគ្គលិក រឺសិក្ខាកាម ដែលជាផ្នែកមួយជួយដល់និស្សិត និងបុគ្គលិកទាំងអស់អោយមានឱកាសទទួលបាននូវដំណឹងដើម្បីអភិវឌ្ឍន៍

អាជីពការងាររបស់ខ្លួន។ ទំព័រកសិកម្ម និងការអភិវឌ្ឍន៍ (ទំព័រទី៥ និងទី៦) គឺជាទំព័រដែលដកស្រង់នូវចំណេះដឹង និងបទពិសោធន៍ទាក់ទងនឹងបច្ចេកទេសកសិកម្ម និងការអភិវឌ្ឍន៍នានា ដើម្បីជាគំរូសំរាប់ការកែលំអនៅក្នុងការធ្វើកសិកម្មរបស់ប្រជាកសិករយើងនៅតាមតំបន់ជនបទនានា។ ទំព័រធនធានធម្មជាតិ និងបរិស្ថាន (ទំព័រទី៧) គឺលើកយកនូវពតិមានផ្សេងៗ គំរូបទពិសោធន៍ល្អៗ ដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋទូទៅ អោយមានការរួមចំណែកធ្វើអោយកាន់តែមានលក្ខណៈប្រសើរឡើងក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព។ ទំព័រស្តីពីជីវិត និងសង្គម (ទំព័រទី៨ និងទី៩) គឺជាទំព័រដែលបង្ហាញអោយឃើញពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាកសិករក្រីក្រ (រស់នៅដោយមានការតស៊ូក្នុងជីវិត) បរិយាកាសទូទៅនៅក្នុងសង្គម ដូចជាទាក់ទងនឹងសីលធម៌ សុជីវធម៌នៅក្នុងសង្គម, យុវជន និងការប្រើប្រាស់ថ្នាំញៀន, អំពើពុករលួយ និងអយុត្តិធម៌ក្នុងសង្គម, ការអប់រំ និងយេនឌ័រ ។ល។ ទំព័រចុងក្រោយសំរាប់អ្នក គឺជាទំព័រដែលផ្តល់នូវមតិយោបល់ និងអនុសាសន៍នានា សំដៅធ្វើការកែលំអស្ថានភាពមិនល្អនានាដែលកំពុងកើតមាននៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន ជាពិសេសដើម្បីបង្កើននូវសមត្ថភាព និងលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងគោលដៅរួមចំណែកកសាងសង្គមមួយដែលល្អ ស្អាតស្អំ និងមានការរីកចំរើន។

- **បណ្ណាល័យ ត្រូវបានបើកជាសាធារណៈ ដល់សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវដទៃទៀត** ចូលអាន និងស្រាវជ្រាវ។ ឯកសារដែលមាននៅក្នុងបណ្ណាល័យអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មានសរុបចំនួនជាង ៤០០ក្បាល ដែលផ្តោតសំខាន់ទៅលើការងារអភិវឌ្ឍន៍សហគមន៍, កសិកម្ម, ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន, ព្រមទាំងឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការងារសង្គមផងដែរ។

## ៣. ការអភិវឌ្ឍន៍សហគមន៍ :

**ក. ការសិក្សាអង្កេត ប្រមូល និងវិភាគទិន្នន័យ :** បានធ្វើការសិក្សាអង្កេត តាមរយៈការប្រើប្រាស់នូវឧបករណ៍ វិធីសាស្ត្រនៃការវាយតំលៃជនបទដោយមានការចូលរួម។ ជាលទ្ធផល ប្រធានបទដែលបានធ្វើការសិក្សាអង្កេត មាន :

- ការសិក្សាអង្កេតពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាកសិករនៅក្នុងភូមិចំនួន៦ នៃឃុំពេជ្រមុនី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ គឺភូមិពេជ្រមុនី, កន្លែងរមាស, ថ្នល់បត់, ទួលព្រីង, ពន្លឺខែ, ត្រពាំងថ្នល់។
- ការសិក្សាអង្កេតពីសក្តានុពលភាព និងលទ្ធភាពនៅក្នុងការធ្វើផលិតកម្មដំណាំពោត នៅក្នុងឃុំពេជ្រមុនី, ឃុំទឹកល្អក់ និងឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

**ខ. ការការបណ្តុះបណ្តាលកសិករ ស្តីពីវិធីសាស្ត្រចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារតាមគោលការណ៍ធម្មជាតិ :** កសិករចំនួន ២០នាក់ នៅភូមិកន្លែងរមាស ឃុំពេជ្រមុនី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ត្រូវបានជ្រើសរើសដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ ដែលប្រព្រឹត្តិទៅ ១ថ្ងៃ

ក្នុង១សប្តាហ៍ និងមានរយៈពេល៥សប្តាហ៍ ដើម្បីអោយកសិករមានឱកាសស្វែងយល់ និងអនុវត្តផ្ទាល់ទៅតាមប្រធានបទនីមួយៗនៅក្រោយពីទទួលបានការបណ្តុះបណ្តាលហើយ។ ប្រធានបទទាំងនោះ រួមមាន :

- ថ្ងៃទី១ : ការចិញ្ចឹមមាន់ និងផលប្រយោជន៍របស់វាសំរាប់គ្រួសារកសិករ, សារៈប្រយោជន៍ និងរបៀបសាងសង់ទ្រុងមាន់, អំពីពូជមាន់
- ថ្ងៃទី២ : ការថែទាំមាន់, ចំណី និងការអោយចំណីមាន់
- ថ្ងៃទី៣ : វិធានការការពារជំងឺមាន់
- ថ្ងៃទី៤ : ការកត់ត្រាតាមដានការចិញ្ចឹមមាន់ និងការវិភាគសេដ្ឋកិច្ចការចិញ្ចឹមមាន់
- ថ្ងៃទី៥ : ការប្រៀបធៀបការចិញ្ចឹមមាន់តាមបែបឧស្សាហកម្ម និងតាមបែបគោលការណ៍ធម្មជាតិ ព្រមទាំងគុណប្រយោជន៍នៃការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ។

**គ. ការធ្វើបង្ហាញពីការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារតាមគោលការណ៍ធម្មជាតិ :** ក្រោយពីបានបណ្តុះបណ្តាលត្រូវបានបញ្ចប់ កសិករគំរូចំនួន ១០រូប ត្រូវបានជ្រើសរើសដើម្បីទទួលបាននូវទុនផលិតកម្មមួយចំនួនសំរាប់ដំណើរការធ្វើការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ។ ក្នុងមួយគ្រួសារ ទទួលបានមាន់ចំនួន៨ក្បាល និងទុនសំរាប់ចូលរួមសាងសង់ទ្រុងមាន់ ដើម្បីចាប់ផ្តើមចិញ្ចឹមមាន់បង្ហាញ។ ជាលទ្ធផល កសិករគោលដៅដែលត្រូវបានជ្រើសរើស បានសាងសង់ទ្រុង និងដំណើរការចិញ្ចឹមមាន់បានយ៉ាងរលូន ដោយមានការចុះដល់មូលដ្ឋាន ដើម្បីផ្តល់ជាប្រឹក្សា និងណែនាំបន្ថែមជាប្រចាំពីការអនុវត្តន៍តាមគោលការណ៍ធម្មជាតិពីបុគ្គលិករបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍។ វេទិកាបែងចែកបទពិសោធន៍ទាក់ទង នឹងការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ នឹងគ្រោងរៀបចំឡើងនៅក្នុងខែមេសា ឆ្នាំ២០០៧ ដែលជាខែចុង ក្រោយសំរាប់ការអនុវត្តគំរោងចិញ្ចឹមមាន់បង្ហាញនេះ ដោយមានការចូលរួម និងធ្វើបទបង្ហាញដោយកសិករគំរូផ្ទាល់ និងបង្កើតអោយមានជានាទីជជែកពិភាក្សាសំដៅធ្វើអោយមានការប្រសើរឡើងថែមទៀតសំរាប់កសិករ ប្រជាពលរដ្ឋទូទៅដែលបានអញ្ជើញអោយចូលរួមលើការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារតាមគោលការណ៍ធម្មជាតិ។